**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី៤
## លើឯកសារអាជ្ញាប័ណ្ណរួម លេខ ០៥៤ ឯអ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៣
## សម្រាប់លោកស្រី អ៊ូច ប៉ោ
## ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារសៃវ៉ា ឃុំតាំងយ៉ាប និងឃុំព្រៃផ្តៅ
## ស្រុកព្រៃកប្បាស ខេត្តតាកែវ
## សម្រាប់ការពង្រីកតំបន់ចែកចាយ

**DECISION ON THE FOURTH REVISION**

**OF THE CONSOLIDATED LICENSE DOCUMENT No. 054 LD**

**DATED SEPTEMBER 9, 2003 FOR MRS. OUCH POR**

**FOR PROVIDING ELECTRICITY SERVICES AT PHSAR SAYVA TOWN,**

**KHUM TAING YAP AND KHUM PREY PHDAO, PREY KABAS DISTRICT,**

**TAKEO PROVINCE**

**FOR EXTENDING DISTRIBUTION AREA**

**ថ្ងៃទី... ខែ... ឆ្នាំ២០០៩**

..., 2009

**ព្រះរាជាណាចក្រកម្ពុជា**

KINGDOM OF CAMBODIA

**ជាតិ សាសនា ព្រះមហាក្សត្រ**

NATION RELIGION KING

**អាជ្ញាធរអគ្គិសនីកម្ពុជា**

ELECTRICITY AUTHORITY OF CAMBODIA

លេខ : -០៩-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៤
# លើឯកសារអាជ្ញាប័ណ្ណលេខ ០៥៤ ឯអ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៣
# សម្រាប់លោកស្រី អ៊ូច ប៉ោ

## DECISION ON THE FOURTH REVISION
## TO THE LICENSE DOCUMENT N° 054 LD DATED SEPTEMBER 9, 2003
## FOR MRS. OUCH POR

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណរួមរបស់លោកស្រី អ៊ូច ប៉ោ លេខ ០៥៤ ឯអ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៣

-Refer to the Consolidated License Document of Mrs. Ouch Por No.054 LD dated September 9, 2003.

-លិខិតស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោកស្រី អ៊ូច ប៉ោ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩

-In accordance with the application for extending distribution area of Mrs. Ouch Por, dated March 13, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the consultation with concerned parties and public, made from ..., 2009 to ..., 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី... នៅថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the decision of Electricity Authority of Cambodia’s Session N°... dated ..., 2009.

# សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលអាជ្ញាប័ណ្ណលេខ ០៥៤ អ ដែលបានផ្តល់ឱ្យលោកស្រី **អ៊ូច ប៉ោ** ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅទីប្រជុំជនផ្សារសែវ៉ា ឃុំតាំងយ៉ាប និងឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១កែសម្រួលថ្មី ។ | **Article 1**<br>To revise License N° 054 L granted to Mrs. Ouch Por to supply electric power at Phsar Sayva Town, Khum Taing Yap and Khum Prey Phdao, Prey Kabas District, Takeo Province to give the right to licensee to extend the existing distribution area as show in the attached map in new revised schedule 1. |
| **ប្រការ ២**<br>ឧបសម្ព័ន្ធទី១ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ០៥៤ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license documents Nº 054 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ ៣**<br>សេចក្តីសម្រេច និងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៥៤ ឯអ។ | **Article 3**<br>This decision and the attached revised Schedule shall be considered as a part of the license documents Nº 054 LD. |
| **ប្រការ ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃនៃឯកសារអាជ្ញាប័ណ្ណលេខ០៥៤ឯអ ត្រូវស្ថិតនៅជាធរមានដដែល។ | **Article 4**<br>The other contents and conditions of the license document N° 054 LD shall remain in force. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៥៤ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០៥៤ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document Nº 054 LD has been deposited in order that the deposited license document Nº 054 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០០៩

Phnom Penh, ..., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF EAC

# ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC Nº... DATED ..., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យលោកស្រី អ៊ូច ប៉ោ ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺ ទីប្រជុំជនផ្សារសៃវ៉ា ឃុំតាំងយ៉ាប និងឃុំព្រៃផ្ដៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ | 1. The authorized distribution Areas, where Mrs. Ouch Por has the right to provide the electricity distribution and supply services at Phsar Sayva Town, Khum Taing Yap and Khum Prey Phdao, Prey Kabas District, Takeo Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយផែនទីកំណត់ព្រំប្រទល់ 054LD-map-Ouch Por-Revision4-2009 ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution Areas is determined by the boundary map 054LD-map-Ouch Por-Revision4-2009 attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោកស្រី អ៊ូច ប៉ោ មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀតពេលនោះលោកស្រី អ៊ូច ប៉ោ ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្ដីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if Mrs. Ouch Por intends to request the extension or the additional distribution areas then Mrs. Ouch Por shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |